**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤០៩៣ មស.ក្រខ

ថ្ងៃ ពុធ ២រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០២០

## សូមគោរពជូន

## សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ឯកឧត្ដម លោកជំទាវ អភិបាលរាជធានី ខេត្ត

**កម្មវត្ថុ ៖** ស្ដីពីការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋសម្រាប់ឆ្នាំ២០២១។

**យោង ៖**
- ច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ៥៩ អនក្រ.តត ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្ដីពីការលើកលែងលក្ខខណ្ឌអាយុ និងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល
- សារាចរណែនាំលេខ០៨.សរណន ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល
- លិខិតលេខ៣៧៥៩ មស.ក្រខ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ដីពីការផ្ដល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័នសម្រាប់ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ឯកឧត្ដម លោកជំទាវ អភិបាលរាជធានី ខេត្ត** មេត្តាជ្រាបថា ក្នុងគោលបំណង ដើម្បីធានាឱ្យដំណើរការនៃការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋសម្រាប់ឆ្នាំ២០២១ ប្រព្រឹត្តទៅស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមុខងារសាធារណៈ សូមលើកឡើងនូវការណែនាំមួយចំនួនដូចខាងក្រោម៖

១.រាល់ការជ្រើសរើសមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង។

២.ប្រធានស្ថាប័ន ក្រសួង អង្គភាពសាមី ត្រូវទទួលខុសត្រូវលើការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល ដោយមានការចូលរួមពីតំណាងក្រសួងមុខងារសាធារណៈ។

៣.ត្រូវរៀបចំគណៈកម្មការប្រឡង ដើម្បីទទួលខុសត្រូវរាល់ដំណើរការប្រព្រឹត្តទៅនៃការប្រឡងចាប់តាំងពីការផ្សព្វផ្សាយជាសាធារណៈ ស្ដីពីបែបបទ និងលក្ខខណ្ឌផ្សេងៗសម្រាប់បេក្ខជនចូលរួមប្រកួតប្រជែង រហូតដល់ការប្រកាសលទ្ធផលជាស្ថាពរ ដោយធានាឱ្យបាននូវតម្លាភាព គណនេយ្យភាព និងជំនឿទុកចិត្ត។



ផ្លូវវ៉ុត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

៤.ត្រូវជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិ សមត្ថភាព និងជំនាញឆ្លើយតបនឹងគោលនយោបាយជាតិ និងតម្រូវការជំនាញសមស្របជាក់ស្តែងរបស់អង្គភាពជំនាញដែលនឹងទទួលក្របខណ្ឌឆ្នាំ២០២១។

៥.លទ្ធផលនៃការប្រឡងត្រូវប្រកាសជាសាធារណៈយ៉ាងយូរ ១ខែ ក្រោយពីបញ្ចប់ការប្រឡង។ បញ្ជីឈ្មោះបេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរត្រូវបញ្ជូនមកសុំការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំឱ្យបេក្ខជនធ្វើកម្មសិក្សាសាកល្បង មុនទទួលបានការតាំងស៊ប់ជាស្ថាពរក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

ក្រសួងមុខងារសាធារណៈ នឹងផ្តល់សេចក្តីណែនាំលម្អិតជាក់ស្តែងបន្ថែមទៀតពាក់ព័ន្ធនឹងបែបបទនីតិវិធីនិងតួនាទីភារកិច្ចរបស់គណៈកម្មការរៀបចំការប្រឡងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

អាស្រ័យហេតុនេះ សូម **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** មេត្តាជ្រាប និងចូលរួមសហការអនុវត្ត ដោយសេចក្តីអនុគ្រោះ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រី**

ព្រុំ សុខា

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

-ឯកសារ កាលប្បវត្តិ